ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣✵៥

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០០២ ស.អ.យ.

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមិនា ឆ្នាំ២០១៥

# សារាចរណែនាំ

## ស្ដីពី

## ការប្រារព្ធពិធីទិវាអន្តរជាតិ ស្ដីពី គ្រួសារ ១៥ ឧសភា ឆ្នាំ២០១៥

អនុវត្តអនុក្រឹត្យលេខ ៤៩ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៥ ស្តីពី ទិវាអន្តរជាតិ ស្តីពីគ្រួសារ ១៥ ឧសភា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមធ្វើការណែនាំដូចខាងក្រោម៖

១-ប្រធានបទសម្រាប់ការប្រារព្ធពិធីទិវាអន្តរជាតិ ស្តីពីគ្រួសារ ១៥ ឧសភា ឆ្នាំ២០១៥ នេះ គឺ « **គ្មានអំពើហិង្សាក្នុងគ្រួសារ គ្រួសារមានសុភមង្គល សង្គមរីកចម្រើន** » ។

២-ផ្សព្វផ្សាយអំពីសារសំខាន់នៃគ្រួសារដែលមានតួនាទី អប់រំ ប្រៀនប្រដៅកូនចៅ ស្តីពី សីលធម៌ វប្បធម៌ ប្រពៃណីទំនៀមទម្លាប់ល្អរបស់សង្គមជាតិ និងចូលរួមចំណែកអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ចជាតិ សង្គមជាតិឱ្យមានវឌ្ឍនភាព ។

៣-បំផុសចលនាកសាងគ្រួសារល្អរួមមាន ៖

ក-មាតា បិតា និងអាណាព្យាបាល ត្រូវអប់រំ បុត្រធីតា ឲ្យខិតខំរៀនសូត្រ និងប្រកាន់ខ្ជាប់នូវសីលធម៌ ដើម្បីក្លាយជាមូលធនបញ្ញាដ៏មានសក្តានុពលក្នុងការរួមចំណែកអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ចជាតិ ដោយចៀសវាងការប្រើប្រាស់ចំណេះដឹង និងបច្ចេកវិទ្យាខុស ដែលអាចបង្កឲ្យមានអំពើហិង្សា ភាពចលាចលដែលនាំមកនូវអស្ថិរភាពសង្គម ឬធ្វើឲ្យបាត់បង់សេចក្តីថ្លៃថ្នូរ ។ ត្រូវប្រែក្លាយចំណេះដឹង និងជំនាញ បទពិសោធន៍ទាំងឡាយ ឲ្យទៅជាឧត្តមប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ និងសង្គមជាតិទាំងមូល ជាពិសេសការលើកកម្ពស់សមភាពយេនឌ័រ និងតម្លៃរបស់ស្ត្រី។

ខ-មាតា បិតានិងអាណាព្យាបាល ត្រូវជួយអប់រំបុត្រធីតា តាមគោលការណ៍នៃព្រហ្មវិហារធម៌ រួមទាំងសីលធម៌ សុជីវធម៌ និងផ្តល់ឱកាសឲ្យកូនប្រុស ស្រី បានរៀនសូត្រខ្ពង់ខ្ពស់អាចរហូតដល់កម្រិតឧត្តមសិក្សា ដើម្បីធ្វើឲ្យគ្រួសារកាន់តែមានភាពចម្រើនរុងរឿង និងសង្គមកាន់តែមានសុខដុមរមនា ពិសេសកាត់បន្ថយវិសមភាពយេនឌ័រនៅក្នុងវិស័យអប់រំ។

គ-ការចែករំលែកព័ត៌មាន និងបទពិសោធន៍ល្អ រវាងគ្រួសារនៅក្នុងសហគមន៍ ក្នុងការ



ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ, ទូរស័ព្ទ/ទូរសារ : (៨៥៥) ២៣ ៧២៦០៨៦
Ministry of Social Affairs, Veterans and Youth Rehabilitation, #788, Monivong Blvd., Phnom Penh, Cambodia. Fax/Phone: (855) 23 726 086

ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ការជួញដូរមនុស្សគ្រប់រូបភាព ការប្រើប្រាស់គ្រឿងញៀន ទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍ និងជំងឺអេដស៍ក្នុងគ្រួសារ និងសហគមន៍ ការធ្វើចំណាកស្រុកដោយគ្មានសុវត្ថិភាព និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម។ល។

៤-ជំរុញអនុវត្តកម្មវិធីជួយសង្គ្រោះដល់ក្រុមជនក្រីក្រងាយរងគ្រោះ ជនអនាថា ជនរងគ្រោះដោយជំងឺកាចសាហាវ និងជនរងគ្រោះដោយសារធម្មជាតិ និងមហន្តរាយនៅតាមសហគមន៍។

៥-ជំរុញសកម្មភាពកម្មវិធីអភិវឌ្ឍន៍គ្រួសារឱ្យមានសុខដុមនីយកម្ម។

៦-ចូលរួមអនុវត្តគោលនយោបាយភូមិ ឃុំមានសុវត្ថិភាព។

៧-កៀរគរប្រភពធនធានពីអង្គការជាតិ អន្តរជាតិ ដៃគូអភិវឌ្ឍ សប្បុរសជន ជួយអភិវឌ្ឍគ្រួសារក្រីក្រងាយរងគ្រោះតាមសហគមន៍។

៨-អំពីការចាត់តាំងប្រារព្ធពិធីទិវាអន្តរជាតិ ស្តីពីគ្រួសារ ១៥ ឧសភា ៖

- អគ្គនាយកដ្ឋានបច្ចេកទេស នាយកដ្ឋានសុខុមាលភាពសង្គម ត្រូវសហការជាមួយផ្នែកពាក់ព័ន្ធរៀបចំទិវាអន្តរជាតិ ស្តីពីគ្រួសារ ១៥ ឧសភា នៅថ្នាក់ក្រសួង។
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ត្រូវចាត់តាំងប្រារព្ធពិធីទិវាអន្តរជាតិ ស្តីពីគ្រួសារ ១៥ ឧសភា នៅតាមរាជធានី ខេត្តនីមួយៗ តាមខ្លឹមសារសារាចរណែនាំនេះ។

ទទួលបានសារាចរណែនាំនេះ គ្រប់អង្គភាពក្រោមឱវាទក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងផ្នែកពាក់ព័ន្ធនានា ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព ។

រដ្ឋមន្ត្រី

វង សូត

**ចម្លងជូន** :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ
-គ្រប់ក្រសួង ស្ថាប័ន
-គ្រប់សាលារាជធានី ខេត្ត
-ឯកសារ កាលប្បវត្តិ